# សេចក្តីប្រកាសព័ត៌មាន

**ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បាន ប្រារព្ធកម្មវិធី Roadshow ដើម្បីបើកសម្ពោធការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ និង ចុះបញ្ជីនៅលើទីផ្សារកំណើននៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក)**

ភ្នំពេញ ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០២០ - ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បាន ប្រារព្ធកម្មវិធី Roadshow តាមរយៈប្រព័ន្ធអនឡាញ ដើម្បីបើកសម្ពោធការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈដែលនឹងត្រូវ ចុះបញ្ជីនៅលើទីផ្សារកំណើននៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក)។ ការចុះបញ្ជីភាគហ៊ុនរបស់ក្រុមហ៊ុន ឌី ប៊ី ឌីនៅលើទីផ្សារកំណើនដំបូងបំផុតនេះ គឺជាសមិទ្ធផលដែលទទួលបានពីការផ្តួចផ្តើមនៃកម្មវិធីឧត្តមភាពលើកទី១ដែលរៀបចំឡើងដោយនិយ័តករមូលបត្រកម្ពុជា (ន.ម.ក)។ ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈនេះ នឹងក្លាយជាគំរូនៃសហគ្រាសធុនតូច និងមធ្យមនៅក្នុងប្រទេសកម្ពុជា។

នាយកគ្រប់គ្រង នៃ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានបញ្ជាក់ថាការបោះផ្សាយលក់ភាគហ៊ុននេះមិនត្រឹមតែជាការប្រមូលប្រភពទុនសម្រាប់ដំណើរការអាជីវកម្មរបស់ក្រុមហ៊ុននោះទេ តែក៏ជាការបង្ហាញនូវភាពរឹងមាំនៃអភិបាលកិច្ចសាជីវកម្ម និងតម្លាភាពរបស់ក្រុមហ៊ុនផងដែរ។

ឯកឧត្តម **ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយក នៃនិយ័តករមូលបត្របានមានវត្តមានជាគណៈអធិបតី នៅក្នុងកម្មវិធី roadshow នេះ។ ឯកឧត្តមមានប្រសាសន៍ថា " ក្រុមហ៊ុន ឌី ប៊ី ឌី ជាសហគ្រាសធុនតូច និងមធ្យមដំបូងបំផុតដែលនឹងចុះបញ្ជីនៅលើទីផ្សារកំណើននៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ។ ឌី ប៊ី ឌី នឹងក្លាយជាសហគ្រាសធុនតូច និងមធ្យមគំរូ ដល់សហគ្រាសធុនតូច និងមធ្យមដទៃទៀតនៅក្នុងប្រទេសកម្ពុជា" ។ " សូមអបអរសាទរ ចំពោះ ក្រុមហ៊ុន ឌី ប៊ី ឌី និង ក្រុមហ៊ុន អេសប៊ីអាយ ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការសម្រេចបានរហូតមកដល់ពេលនេះ "។

នៅក្នុងព្រឹត្តិការណ៍នេះផងដែរ ឯកឧត្តម **ហុង សុហួរ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយក នៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានមានប្រសាសន៍ថា «កម្មវិធី Roadshow ស្ទើរតែជាដំណាក់កាលចុងក្រោយ សម្រាប់ក្រុមហ៊ុន ឌី ប៊ី ឌី ដើម្បីក្លាយជាក្រុមហ៊ុនដែលចុះបញ្ជីនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហើយក៏ជាក្រុមហ៊ុនដំបូងបំផុត ដែលចុះបញ្ជីនៅលើទីផ្សារកំណើនផងដែរ។ ការចុះបញ្ជីនេះ នឹងទទួលបាននូវទំនុកចិត្ត ការជឿជាក់ និង ប្រភពទុនខាងក្រៅកាន់តែច្រើន ពីសាធារណៈជន ហើយនឹងមានអត្ថប្រយោជន៍កាន់តែច្រើន ជាពិសេសសម្រាប់ សហគ្រាសធុនតូច និងមធ្យម នៅកម្ពុជា»។

ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យួរីធី ដែលជាក្រុមហ៊ុនធានាទិញមូលបត្រ បានចូលរួមចំណែកគាំទ្រលើទីផ្សារមូលបត្រកម្ពុជាតាំងពីការបង្កើតក្រុមហ៊ុនជាមួយនឹងសមិទ្ធផលប្រវត្តិសាស្ត្ររួមមាន ការបោះផ្សាយមូលបត្រ

បំណុលដំបូងបំផុត និងជួយអោយក្រុមហ៊ុន ឌី បី ឌី ចុះបញ្ជីភាគហ៊ុនរបស់នៅលើទីផ្សារកំណើនដំបូងបំផុតនេះនាពេលបច្ចុប្បន្ននេះ។ ចាប់តាំងពីការចាប់ផ្តើម ទីផ្សារមូលបត្របានរីកចម្រើនជាលំដាប់ហើយប្រតិបត្តិការជាច្រើនត្រូវបានបញ្ចប់ជារៀងរាល់ឆ្នាំដោយសារមានការគាំទ្រជាបន្តពីអាជ្ញាធរពាក់ព័ន្ធរួមមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និយ័តករមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងភាគីពាក់ព័ន្ធដទៃទៀត។ លោក **សេង ចាន់ជឿន** នាយកប្រតិបត្តិ ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយ្យូរីធី បានឲ្យដឹងថា «វាជាកិត្តិយសដ៏អស្ចារ្យមួយក្នុងការរៀបចំកម្មវិធី Roadshow នេះ និងដើម្បីជួយអោយក្រុមហ៊ុន អាចធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និងចុះបញ្ជីនៅលើទីផ្សារកំណើន។ តាមរយៈការបោះផ្សាយនេះ យើងបានបង្កើតយន្តការថ្មីមួយដែលងាយស្រួលដល់ សហគ្រាសធុនតូច និងមធ្យម ដើម្បីឡើងផ្សារហ៊ុន»។

## អំពីក្រុមហ៊ុន ឌី បី ឌី អ៊ិនជីនារីង ម.ក

ក្រុមហ៊ុន ឌី បី ឌី អ៊ិនជីនារីង ម.ក ហៅកាត់ថា ("ឌី បី ឌី") បានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ និងជាក្រុមហ៊ុនដែលមានលក្ខណៈពហុជំនាញប្រកបដោយបទពិសោធន៍ឈានមុខគេក្នុងវិស័យវិស្វកម្ម និងសំណង់នៅប្រទេសកម្ពុជា។ ឌី បី ឌី មានបុគ្គលិកជាង ៧០០ នាក់ និងមានជំនាញខាងផ្នែកមេកានិច អគ្គិសនី ប្រព័ន្ធបំពង់ទឹក និងសំណង់ស៊ីវិល និងមានកំណត់ត្រាល្អបំផុតក្នុងការ ផ្តល់ផលិតផល និងសេវាកម្មដែលមានគុណភាពខ្ពស់ និងទទួលបាននូវការពេញចិត្តយ៉ាងខ្លាំងពីសំណាក់អតិថិជន។

## អំពី ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយ្យូរីធី ៖

ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយ្យូរីធី គឺជាក្រុមហ៊ុនមូលបត្រឈានមុខគេនៅកម្ពុជា ដែលផ្តល់ជូននូវសេវាវិនិយោគគ្រប់បែបរួមមាន ការធានាទិញមូលបត្រ ការប្រឹក្សាយោបល់ ការរួមបញ្ចូលគ្នា និងការទិញក្រុមហ៊ុន និងឈ្មួញជើងសាមូលបត្រផងដែរ។ នៅក្នុងឆ្នាំ ២០១៨ ក្រុមហ៊ុន ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយ្យូរីធី ត្រូវបានទទួលស្គាល់ជា "Best Corporate and Investment Bank" ដោយទស្សនាវដ្តី Asiamoney។ ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយ្យូរីធី ត្រូវបានបង្កើតឡើងនៅក្នុងខែកុម្ភៈ ឆ្នាំ២០១០ ហើយគឺជាក្រុមហ៊ុនមូលបត្ររបស់ជប៉ុនដំបូងគេបង្អស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានអាជ្ញាបណ្ណពេញលេញពីនិយ័តករមូលបត្រកម្ពុជាដើម្បីធ្វើប្រតិបត្តិការអាជីវកម្មមូលបត្រ។ ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយ្យូរីធី បានទទួលនូវជោគជ័យពីប្រតិបត្តិការជាច្រើនដែលរួមមាន មូលបត្រកម្មសិទ្ធិ របស់ កំពង់ផែក្រុងព្រះសីហនុ (CSX listing: PAS) មូលបត្រកម្មសិទ្ធិរបស់តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (CSX listing: PPSP) សញ្ញាបណ្ណសាជីវកម្មដំបូងនៅកម្ពុជាដែលបោះផ្សាយហត្ថាកសិករលីមីតធីត (CSX listing: HKL21A) ធនាគារ ABA (CSX listing: ABAA22A) ក្រុមហ៊ុន អ អិម អេ ខេមបូឌា (CSX listing: RMAC25A) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ (CSX listing: PRA23A) និងគម្រោងហិរញ្ញវត្ថុផ្សេងៗជាច្រើនទៀត។

**សម្រាប់ការសាកសួរព័ត៌មានពាក់ព័ន្ធនឹងក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក**

ការសាកសួរព័ត៌មាន៖ services@dbdengineering.com

+៨៥៥ ៧៨ ៧០០ ៥៩៨

គេហទំព័រក្រុមហ៊ុន៖ https://dbdengineering.com

**សម្រាប់ការសាកសួរព័ត៌មានពាក់ព័ន្ធនឹងក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី**

ការសាកសួរព័ត៌មាន៖ cf@sbiroyal.com

+៨៥៥ ២៣ ៩៩៩ ៥៩៥

+៨៥៥ ៧៨ ៧៧៧ ០៦៤

គេហទំព័រក្រុមហ៊ុន អេសប៊ីអាយ៖ www.sbiroyal.com